# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
## អគ្គនាយកដ្ឋានស្រាវជ្រាវ
## នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**


- ការនាំចេញកម្ពុជាសម្រេចបាន ១១,០៨ប៊ីលានដុល្លារ អាមេរិក ក្នុងរយៈពេល ០៨ខែ នៃឆ្នាំ២០២១
- ការនាំចេញ-នាំចូលកម្ពុជាឆ្លងកាត់តាមតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ
- ក្រុមហ៊ុន Ford គ្រោងបោះទុនវិនិយោគ ២១លានដុល្លារសង់រោងចក្រផ្គុំ និងតម្លើងរថយន្ត នៅកម្ពុជា
- ផែនការឈានបើកទទួលភ្ញៀវទេសចរអន្តរជាតិឡើងវិញកំពុងបង្ហាញពីភាពវិជ្ជមានច្រើន
- តើគម្រោងខ្សែក្រវាត់ និងផ្លូវរបស់ចិនជួយជំរុញកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាយ៉ាងណាខ្លះ?
- កម្ពុជានាំទំនិញទៅអាមេរិកនៅតែបន្តកើនឡើង រហូតដល់៤០% ក្នុងរយៈពេល៨ខែឆ្នាំនេះ
- ដំណាំលម្ញីក្រហម មានទីផ្សារមិនចាញ់លម្ញីលឿង ប៉ុន្តែមិនសូវមានអ្នកដាំ
- ឯកឧត្តម ឧកញ៉ា ម៉ុង ឬទ្ធី លើកទឹកចិត្តឱ្យកសិករចិញ្ចឹមជ្រូកព្រៃ ដ្បិតមានតម្លៃខ្ពស់មិនចាញ់ជ្រូកកណ្តុរ
- ពាណិជ្ជកម្មរបស់ម៉ាឡេស៊ី និងថៃសម្រាប់ខែកក្កដា ឆ្នាំ២០២១
- តើចរន្តទិញទំនិញតាមអនឡាញនៅអាស៊ីអាគ្នេយ៍កើនឡើងកម្រិតណាក្នុងអំឡុងពេលវិបត្តិកូវីដ-១៩?
- ផលិតកម្មវៀតណាមធ្លាក់ចុះ បង្អាក់ដល់ការផ្គត់ផ្គង់ជាសកល
- ម៉ាឡេស៊ីគ្រោងនឹងបង្កើនពិដានបំណុលរដ្ឋាភិបាល ដល់ ៦៥% នៃផ.ស.ស
- ថៃ ជំរុញការនាំចេញផ្លែទុរេនកាន់តែខ្លាំង
- គណបក្សប្រជាធិបតេយ្យនៃសហរដ្ឋអាមេរិកបានស្នើ ដំឡើងពន្ធលើមូលធនដល់ទៅ២៨,៨%
- ជំងឺកូវីដ១៩-បំប្លែងថ្មីអាចធ្វើឱ្យមូលនិធិមូលធននៃសហរដ្ឋអាមេរិកប្រឈមមុខនឹងលំហូរចេញ



ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី — អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា — អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី — ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរៈ — អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២១ លេខ ៖ ៨៥

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## ការនាំចេញកម្ពុជាសម្រេចបាន ១១,០៨ប៊ីលានដុល្លារអាមេរិក ក្នុងរយៈពេល ០៨ខែ នៃឆ្នាំ២០២១




*ប្រភព៖ Khmer Post Asia ២០២១*

ការនាំចេញកម្ពុជា សម្រេចបានក្នុងទំហំទឹកប្រាក់ចំនួន ១១,០៨ប៊ីលានដុល្លារអាមេរិក ក្នុងរយៈពេល ០៨ខែដំបូង នៃឆ្នាំ២០២១។ តួលេខនេះ គឺធ្លាក់ចុះ ៥,៣% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន នេះបើយោងតាមរបាយការណ៍ផ្លូវការដែលចេញផ្សាយដោយក្រសួងពាណិជ្ជកម្មកម្ពុជា។

ទោះយ៉ាងណា របាយការណ៍នេះពុំបានបញ្ជាក់ពីទីផ្សារនាំចេញចម្បង និងប្រភេទផលិតផលសម្រាប់ធ្វើការនាំចេញរបស់កម្ពុជានោះទេ ប៉ុន្តែ ក្រសួងបានលើកឡើងថា នៅក្នុងខែកក្កដា ឆ្នាំ២០២១ ទីផ្សារនាំចេញចម្បងរបស់កម្ពុជា រួមមាន៖ សហរដ្ឋអាមេរិក សហភាពអឺរ៉ុប ប្រទេសកាណាដា ជប៉ុន ចិន កូរ៉េខាងត្បូង និងប្រទេសសមាជិកអាស៊ាន។

យោងតាមសម្តីរបស់លោក លឹម ហេង អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា បានឱ្យដឹងថា៖ ពាណិជ្ជកម្មកម្ពុជាជាមួយដៃគូនៅតែមាននិន្នាការល្អ។ លោកបញ្ជាក់ថា ការនាំចេញផលិតផលកសិកម្ម និងផលិតផលមិនមែនកាត់ដេរ ដូចជាកង់ កំពុងបង្ហាញនិន្នាការកើនឡើង បើទោះបីជាការនាំចេញផលិតផលកាត់ដេរមានកំណើនអវិជ្ជមានក្នុងការនាំចេញ ក្នុងអំឡុងពេលនៃការរាតត្បាតពីជំងឺកូវីដ-១៩ ក្តី។

បន្ថែមពីនេះ ជាមួយនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងពហុភាគី កម្ពុជាត្រូវបានរំពឹងថានឹងទទួលបានការវិនិយោគបន្ថែមទៀតដែលនឹងជំរុញទាំងការនាំចេញផលិតផលសម្រេច និងការនាំចូលវត្ថុធាតុដើមសម្រាប់ផ្គត់ផ្គង់សង្វាក់ផលិតកម្ម ដែលនឹងផ្តល់នូវអត្ថប្រយោជន៍ដល់ចំណូលពន្ធផងដែរ។

ជាមួយគ្នានេះ យោងតាមប្រសាសន៍របស់ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា ថ្លែងនៅក្នុងសន្និសីទអន្តរជាតិលើកទី៥ ស្តីពីការកសាងប្រទេសក្រោមប្រធានបទ «យុទ្ធសាស្ត្រថ្មីប្រឌិតសម្រាប់ការស្តារវិបត្តិ និងការកសាងប្រទេស» ដែលប្រព្រឹត្តទៅនាថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ កន្លងមកបានឱ្យដឹងថា៖ កម្ពុជានឹងអាចបើកដំណើរការឡើងវិញនូវសកម្មភាពសេដ្ឋកិច្ច-សង្គមយ៉ាងពេញលេញក្នុងពេលឆាប់ៗនេះ ដោយសារការធ្លាក់ចុះជាលំដាប់នូវ អត្រាឆ្លងថ្មី ផ្ទុកជំងឺធ្ងន់ធ្ងរ និងស្លាប់ពីជំងឺកូវីដ-១៩ ក្នុងរយៈពេលមួយខែចុងក្រោយនេះ។

ទោះយ៉ាងនេះក្តី ដើម្បីសម្រេចបាននូវគោលដៅខាងលើ ការដាក់ចេញនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈសមស្របដែលជានានូវការបែងចែក និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព គឺជាគន្លឹះដ៏សំខាន់៕

*ដោយ ស៊ិន សុភាព៌*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Khmer Post Asia ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២១*

## ការនាំចេញ-នាំចូលកម្ពុជាឆ្លងកាត់តាមតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ មានតម្លៃសរុប ១,៣៧ប៊ីលានដុល្លារ ក្នុងរយៈពេល ០៨ខែ ដើមឆ្នាំ២០២១



The value of imports and exports passing through the Sihanoukville Special Economic Zone (SSEZ) was $1.373 billion in the January-August period, up 44.37 per cent on a yearly basis. Photo supplied

*ប្រភព៖ Phnom Penh Post ២០២១*

ការនាំចេញ-នាំចូលកម្ពុជាឆ្លងកាត់តាមតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (SSEZ) មានតម្លៃសរុប ១,៣៧ប៊ីលានដុល្លារអាមេរិក ក្នុងរយៈពេល ០៨ខែ ដំបូង នៃឆ្នាំ២០២១ ពោលគឺកើនឡើង ៤៤,៤% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

កំណើននេះ បានបង្ហាញថាតម្រូវការទំនិញកម្ពុជានៅតែស្ថិតក្នុងសញ្ញាណវិជ្ជមាន ក្នុងអំឡុងពេលនៃការរាតត្បាតពីជំងឺកូវីដ-១៩ ជាពិសេសផលិតផលកសិកម្ម បើទោះបីការនាំចេញនៅតែត្រូវបានញាំញីដោយថ្លៃដឹកជញ្ជូនខ្ពស់ និងកង្វះកុងតឺន័រ នេះបើយោងតាមសម្តីរបស់លោក ជា ច័ន្ទតារា ប្រធានសមាគមពាណិជ្ជកម្មដឹកជញ្ជូន។

លោកបានបញ្ជាក់ដែរថា សង្វាក់ផ្គត់ផ្គង់របស់រោងចក្រនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស មិនបានរងផលប៉ះពាល់ពីការរាតត្បាតនៃជំងឺកូវីដ-១៩ទេ ដូច្នេះការផលិតនៅតែបំពេញតាមតម្រូវការពីការបញ្ជាទិញខាងក្រៅ។

ក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ បានកោតសរសើរចំពោះការរួមចំណែករបស់តំបន់សេដ្ឋកិច្ចពិសេស(SEZ) ក្នុងកាលៈទេសៈនៃការប្រឈមនឹងជំងឺកូវីដ-១៩ តាមរយៈការជំរុញយ៉ាងខ្លាំងដល់វឌ្ឍនភាពនៃការនាំចេញរបស់កម្ពុជា និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានានូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងប្រតិបត្តិការអាជីវកម្មរបស់សហគ្រាស។

យោងតាមប្រតិបត្តិករ តំបន់សេដ្ឋកិច្ចពិសេស SSEZ បានគ្រប់គ្រងការនាំចេញ និងនាំចូល ក្នុងតម្លៃទឹកប្រាក់ ១,៥៦ប៊ីលានដុល្លារអាមេរិក កាលពីឆ្នាំ ២០២០ ដែលកើនឡើង ២៦,៥% ធៀបនឹងឆ្នាំ ២០១៩។ គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២០ តំបន់សេដ្ឋកិច្ចពិសេសនេះ មានអាជីវកម្មចំនួន ១៦៥ និងផ្តល់ការងារចំនួន ៣០ ០០០កន្លែង៕

*ដោយ ស៊ិន សុភាព៌*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Phnom Penh Post ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២១*

## ក្រុមហ៊ុន Ford គ្រោងបោះទុនវិនិយោគ ២១លានដុល្លារ សង់រោងចក្រ ផ្គុំ និងតម្លើងរថយន្ត នៅកម្ពុជា




*ប្រភព ៖ cambonomist*

ក្រុមហ៊ុន RMA AUTOMOTIVE CO.,LTD គ្រោងបោះទុនវិនិយោគ ប្រមាណ ២១លានដុល្លារអាមេរិក ដើម្បីសាងសង់រោងចក្រផ្គុំ និងតម្លើងរថយន្តដែលមានទីតាំងស្ថិតនៅស្រុក ក្រគរ ខេត្តពោធិ៍សាត់។ គម្រោងវិនិ

យោគនេះ បានបញ្ចប់ការសិក្សារួចស្រេចហើយ និងកំពុងរង់ចាំការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍កម្ពុជា(CDC) បានបើកកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ដើម្បីពិភាក្សាលើគម្រោងវិនិយោគរោងចក្រផ្គុំ និងតម្លើងរថយន្ត (ផលិត ចែកចាយ លក់ និងសេវាកម្ម) របស់ក្រុមហ៊ុន RMA AUTOMOTIVE (CAMBODIA) CO.,LTD ដែលមានការចូលរួមពីអភិបាលខេត្តពោធិ៍សាត់ផងដែរ។

ជាការឆ្លើយតប ឯកឧត្តម ម៉ៅ ធនិន អភិបាលខេត្តពោធិ៍សាត់ បានគាំទ្រយ៉ាងពេញទំហឹង ចំពោះគម្រោងនេះ ក្នុងការសាងសង់រោងចក្រផ្គុំ និងតម្លើងរោងចក្រ Ford ដែលមានទីតាំងស្ថិតនៅស្រុក ក្រគរ ខេត្តពោធិ៍សាត់ ដែលធ្វើឱ្យខេត្តពោធិ៍សាត់អាចបង្កើនគម្រោងវិនិយោគ និងបង្កើនឱកាសការងារបន្ថែមដល់ពលរដ្ឋរបស់ខ្លួន៕*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ cambonomist ចេញផ្សាយថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០២១*

## ផែនការឈានបើកទទួលភ្ញៀវទេសចរអន្តរជាតិឡើងវិញ កំពុងបង្ហាញពីភាពវិជ្ជមានច្រើន



*រូបភាព៖ Internet*

ចរន្តទេសចរណ៍ផ្ទៃក្នុងរបស់កម្ពុជា ចាប់ផ្តើមរើបខ្លួនឡើងវិញជាបណ្តើរៗហើយនៅមួយរយៈចុងក្រោយនេះ នៅចំពេលដែល កម្ពុជាសម្រេចបានការចាក់វ៉ាក់សាំងជូនពលរដ្ឋបានកាន់តែច្រើន គឺសម្រេចបានប្រមាណជាង ៧០% នៃចំនួនប្រជាជនសរុប ១៦លាននាក់។ លទ្ធផលនេះ បង្ហាញឱ្យឃើញពីភាពវិជ្ជមានកាន់តែច្រើនក្នុងការឈានទៅបើកទទួលទេសចរអន្តរជាតិឡើងវិញនៅពេលខាងមុខនេះ។ កត្តាចម្បងដែលជំរុញឱ្យផែនការរបស់រាជរដ្ឋាភិបាលសម្រេចជោគជ័យ ក្នុងការបើកទេសចរណ៍ឡើងវិញ គឺអាស្រ័យលើយុទ្ធនាការចាក់វ៉ាក់សាំងជូនពលរដ្ឋឱ្យបានគ្រប់ៗគ្នា។

នៅសប្តាហ៍ដំបូង ក្នុងខែកញ្ញា កម្ពុជាមានភ្ញៀវទេសចរផ្ទៃក្នុង សរុបជាង ៥ម៉ឺននាក់ បានដើរកម្សាន្តនៅតាមតំបន់រមណីយដ្ឋាននានា ទូទាំងប្រទេស។

ស្ថានភាពវិស័យទេសចរណ៍ នារយៈពេលចុងក្រោយនេះ ហាក់មានភាពប្រសើរបន្តិចក្រោយការចាក់វ៉ាក់សាំងជិតសម្រេចនូវផែនការដែលបានគ្រោងទុក ពិសេសនៅតាមតំបន់រមណីយដ្ឋាននានា មានចលនាដើរកម្សាន្តទេសចរក្នុងស្រុកឡើងវិញ។

យោងតាមរបាយការណ៍របស់ក្រសួងទេសចរណ៍ នៅឆមាសទី១ ក្នុងឆ្នាំ២០២១ កម្ពុជា ទទួលបានភ្ញៀវទេសចរអន្តរជាតិ ប្រមាណ១០ម៉ឺននាក់ ថយចុះ ៩១% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ដោយឡែក សម្រាប់ទេសចរផ្ទៃក្នុងវិញ ដែលមានចំនួនសរុបជិត ២លាននាក់ បានថយចុះ៣៧%៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ cambonomistចេញផ្សាយថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០២១*

## តើគម្រោងគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ របស់ចិន ជួយជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាយ៉ាងណាខ្លះ?



*ប្រភព ៖ cambonomist រូបភាព៖ ក្រសួងការបរទេសកម្ពុជា*

គម្រោងគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ គឺជាការតភ្ជាប់តំបន់អាស៊ី ទៅតំបន់អឺរ៉ុប ដែលជួយបង្កើនទំនាក់ទំនង រវាងប្រជាជន និងប្រជាជន នៅតំបន់អាស៊ី និងអឺរ៉ុប ឱ្យកាន់តែជិតស្និត។ គម្រោងនេះជួយពង្រឹងផ្នែកនយោបាយ ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ជាដើម។

សម្រាប់កម្ពុជាគម្រោងគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ ជាការចូលរួមចំណែកដ៏សំខាន់ ក្នុងការអភិវឌ្ឍន៍ជាតិ និងជំរុញកំណើនសេដ្ឋកិច្ច។ នេះគឺជាកាលានុ-វត្តភាពដ៏សំខាន់ ដែលអាចទាក់ទាញអ្នកនិយោគចិនចូលមកកម្ពុជា ដើម្បីប្រែក្លាយប្រទេសមួយដែលពឹងផ្អែកលើវិស័យ កសិកម្ម ទៅជាប្រទេសដែលពឹងផ្អែកលើវិស័យឧស្សាហកម្ម។

ជាក់ស្តែងសម្រាប់កម្ពុជា មានគម្រោងធំៗ ចំនួន២ ដែលនឹងទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ រួមមាន ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ ចំងាយ ១៩០គីឡូម៉ែត្រ និងតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងខេត្តព្រះសីហនុ ដែលមានរោងចក្ររហូត ២០០រោងចក្រ។ បន្ថែមពីនេះ គម្រោងព្រលានយន្តហោះថ្មីមួយ នៅខេត្តសៀមរាប អាចនឹងទទួលភ្ញៀវទេសចរប្រមាណ ២០លាននាក់ ក្នុងមួយឆ្នាំៗ ទៅថ្ងៃអនាគត។

បើតាមការអះអាងរបស់រដ្ឋមន្ត្រីការបរទេសកម្ពុជា ទំនាក់ទំនងរវាងកម្ពុជា និងចិន គឺផ្អែកទៅលើការផ្តល់ផលប្រយោជន៍ឱ្យគ្នា និងគោរពគ្នាទៅវិញទៅមក ជាមួយនឹងភាពស្មោះត្រង់ជាមួយគ្នា។

តាមតួលេខពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឱ្យដឹងថា បំណុលដែលកម្ពុជាជំពាក់ចិនមានដល់ទៅជិត ៤ពាន់លានដុល្លារ ឬស្មើនឹងជាង៤៣% នៃបំណុលសាធារណៈសរុបពីបរទេស៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖cambonomistចេញផ្សាយថ្ងៃទី១២ខែកញ្ញាឆ្នាំ ២០២១*

## ការនាំចេញពីកម្ពុជាទៅអាមេរិក បន្តកើនឡើងរហូតដល់៤០% ក្នុងរយៈពេល៨ខែដំបូងនៃឆ្នាំនេះ



*ប្រភព ៖ cambonomist*

ការនាំចេញទំនិញរបស់កម្ពុជានៅតែកើនខ្លាំងក្នុងរយៈពេល៨ខែដើមឆ្នាំ២០២១នេះ បើទោះបីជាកូវីដ១៩ បាននិងកំពុងបន្តអុកឡុកខ្លាំងក្តី។ ជាក់ស្តែងនៅរយៈពេល៨ខែឆ្នាំនេះ ការនាំចេញទំនិញរបស់កម្ពុជាទៅសហរដ្ឋអាមេរិក សម្រេចបានជាង ៤ ៦០០លានដុល្លារអាមេរិក កើនឡើង៤០% ខណៈការនាំចូលពីសហរដ្ឋអាមេរិកកើនឡើងជាង ៦០% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ទំហំពាណិជ្ជកម្មសរុបរវាងប្រទេសទាំងពីរ បានឈានដល់ជិត៥ពាន់

លានដុល្លារ កើនឡើងជាង៤០% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

តាមរយៈតួលេខនេះអាចបញ្ជាក់បានថា ការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ ជាសកលមិនបានបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរនោះទេ ទោះបីបញ្ហានេះបានធ្វើឱ្យមានការរាំងស្ទះមួយចំនួនដល់ការដឹកជញ្ជូនក៏ដោយ។

កត្តាដែលធ្វើឱ្យការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាមេរិក នៅតែអាចរក្សាបាននូវកំណើននេះ គឺដោយសារកម្ពុជាទទួលបានប្រព័ន្ធអនុគ្រោះពន្ធទូទៅពីសហរដ្ឋអាមេរិក(GSP) គួបផ្សំតម្រូវការកើនឡើង។ វិបត្តិនយោបាយនៅមីយ៉ាន់ម៉ា ក៏ជាកត្តារួមចំណែកធ្វើឱ្យការនាំចេញរបស់កម្ពុជាកើនឡើងផងដែរ។ ការនាំចូលពីសហរដ្ឋអាមេរិកមកកម្ពុជាមានការកើនឡើង ដែលបានបង្ហាញពីភាពល្អប្រសើរនៃចរន្តសេដ្ឋកិច្ចកម្ពុជា។

ទំនិញដែលកម្ពុជានាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក រួមមាន សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ ខណៈកម្ពុជានាំចូលពីអាមេរិកភាគច្រើន គឺជារថយន្ត និងគ្រឿងអគ្គិសនីជាដើម។

គួររំលឹកថា ទំហំពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា-សហរដ្ឋអាមេរិកកាលពីឆ្នាំ២០២០ មានទំហំទឹកប្រាក់ជិត ៧ពាន់លានដុល្លារអាមេរិក កើនឡើងជិត ១៨% បើធៀបនឹងឆ្នាំ២០១៩ ដែលមានទំហំទឹកប្រាក់ជិត ៦ពាន់លានដុល្លារអាមេរិក៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖Cambonomistចេញផ្សាយថ្ងៃទី១៤ខែកញ្ញាឆ្នាំ២០២១។*

## ដំណាំលម៉ើក្រហម មានទីផ្សារមិនចាញ់លម៉ើលឿង ប៉ុន្តែ មិនសូវមានអ្នកដាំ



*ប្រភព ៖ ខេមបូណ្ឌមីស*

មនុស្សភាគច្រើនស្គាល់តែប្រភេទលម៉ើលឿង ប៉ុន្តែក្រៅពីពូជលម៉ើលឿងនៅកម្ពុជា ក៏មានដាំប្រភេទពូជលម៉ើក្រហមដែរ។ ដំណាំលម៉ើ កំពុងមានទីផ្សារគួរឱ្យកត់សម្គាល់ ប៉ុន្តែការដាំដុះដំណាំនេះ នៅមិនទាន់មាន ទ្រង់ទ្រាយធំនៅឡើយទេ។ លម៉ើលឿង និងលម៉ើក្រហមមានតម្រូវការទីផ្សារ និងតម្លៃខ្ពស់ដូចគ្នា។

អ្នកស្រី កង សុជា ជាកសិករដាំលម៉ើក្រហមបានរៀបរាប់ថា រូបគាត់បានប្រកបរបរដំណាំលម៉ើក្រហម ៥ ឆ្នាំមកហើយ នៅក្នុងស្រុកសូទ្រនិគម ខេត្តសៀមរាប។

ការជ្រើសយកការដាំដុះដំណាំលម៉ើក្រហមនេះ ព្រោះដោយសារតែឃើញភាគច្រើនគេនិយមដាំលម៉ើលឿង។ មួយវិញទៀត ដោយសារតែអ្នកស្រីសង្កេតឃើញថា ទីផ្សារបច្ចុប្បន្ននេះ លម៉ើក្រហមក៏មានតម្លៃមិនចាញ់លម៉ើលឿងប៉ុន្មានដែរដោយសារលម៉ើក្រហមនេះ គឺសម្រាប់តែផ្គត់ផ្គង់ទីផ្សារនៅក្នុងស្រុកប៉ុណ្ណោះ ក្នុងតម្លៃមានចន្លោះពី៤ម៉ឺន ទៅ៥ម៉ឺនរៀល ក្នុងមួយគីឡូក្រាម។

ការដាំលម៉ើ ក៏នៅជួបបញ្ហាមួយចំនួនដែរក្នុងការរើសពូជមកដាំខុស ដោយសារតែដាំចំលម៉ើឈ្មោល។

ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប ក៏បានបញ្ជាក់ដែរថា បច្ចុប្បន្នការដាំដុះលម៉ើក្រហមកំពុងមានសន្ទុះកើនឡើងជាងមុន

ព្រោះ មានទីផ្សារល្អ និងតម្លៃថ្លៃ។ ប្រសិនបើដំណាំលម៉ើនេះ មានទីផ្សារកាន់តែល្អប្រសើរទៅមុខទៀតនោះ ខាងក្រសួង នឹងមានការចុះមកបង្ហាត់បង្រៀនកសិករបន្ថែម អំពី បច្ចេកទេសនានា។

បើទោះបីជាទីផ្សារលម៉ើនៅពេលនេះ កំពុងតែមានការគាំទ្រក៏ពិតមែន ប៉ុន្តែដំណាំឈើហូបផ្លែមួយនេះនៅតែមិនទាន់អាចចាត់ចូលទៅក្នុងចំណោមប្រភេទដំណាំ កសិឧស្សាហកម្មជួរមុខនៅឡើយទេ ដោយសារតែការដាំដុះដំណាំនេះនៅមានជាលក្ខណៈជាទ្រង់ទ្រាយតូចនៅឡើយ៕ *ដោយ ម៉ែន ខែមរៈ* *ប្រភព៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០២១*

## ឯកឧត្តម ឧកញ៉ា ម៉ុង ឫទ្ធី លើកទឹកចិត្តឱ្យកសិករចិញ្ចឹមជ្រូកព្រៃ ដ្បិតមានតម្លៃខ្ពស់មិនចាញ់ជ្រូកកណ្តុរ



*ប្រភព ៖ ខេមបូណូមីស*

បច្ចុប្បន្ន ទីផ្សារសត្វជ្រូក ដែលមានទំហំតូចៗ ដូចជា ជ្រូកកណ្តុរ និងជ្រូកព្រៃកំពុងកើនឡើងខ្ពស់ ប៉ុន្តែចំនួនអ្នកចិញ្ចឹមហាក់នៅមានកម្រិត ពិសេសចំពោះជ្រូកព្រៃតែម្តង។

ឯកឧត្តម ឧកញ៉ា ម៉ុង ឫទ្ធី បានលើកទឹកចិត្តឱ្យកសិករចិញ្ចឹមពូជជ្រូកព្រៃព្រោះមានទីផ្សារមិនចាញ់ជ្រូកកណ្តុរប៉ុន្មាននោះទេ។ ឯកឧត្តមបានចិញ្ចឹមជ្រូកព្រៃ២០ក្បាលដែរ ដើម្បីកម្សាន្តនៅក្នុងតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ស្ថិតក្នុងខេត្តកំពង់ស្ពឺ។ ផ្តើមពីការចិញ្ចឹមបែបកម្សាន្ត ក៏បានទទួលលទ្ធផលល្អ និងមានការរីកលូតលាស់ជាបន្តបន្ទាប់។ បច្ចុប្បន្ន ឯកឧត្តម បានចិញ្ចឹមបន្ថែមសរុប៥០០ក្បាល។ ឯកឧត្តម បានលើកទឹកចិត្ត ដល់កសិករគួរចាប់អារម្មណ៍ចិញ្ចឹមជ្រូកព្រៃធ្វើអាជីវកម្ម។ ប៉ុន្តែការចិញ្ចឹមជ្រូកព្រៃ មិនងាយស្រួល ដែលមិនមែនអ្នកណាក៏សុទ្ធតែអាចចិញ្ចឹមបានដែរ។ កន្លងមក ឯកឧត្តមបានចែកពូជដល់កសិករ ដែលចង់ចិញ្ចឹម ប៉ុន្តែកសិករខ្លះចិញ្ចឹមមិនបានប៉ុន្មានផង ក៏បោះបង់ព្រោះខ្វះបច្ចេកទេស និងបទពិសោធន៍ ចិញ្ចឹម។ ដើម្បីចិញ្ចឹមជ្រូកឱ្យបានលទ្ធផលល្អ គឺត្រូវមើលថែដិតដល់ និងមានបច្ចេកទេសចិញ្ចឹមត្រឹមត្រូវ។ ការចញ្ចឹមជ្រូកព្រៃ គឺមានរយៈពេល១៥០ថ្ងៃ កសិករ នឹងអាចទទួលផល។

ជ្រូកព្រៃមានមាឌតូចៗ ស្រដៀងនឹងជ្រូកកណ្តុរដែរ ដែលមនុស្សភាគច្រើន កំពុងពេញនិយមបរិភោគ។ រីឯតម្លៃវិញ បើសិនជ្រូកមានទម្ងន់ចាប់ពី ២០ គីឡូក្រាមឡើងទៅ អាចលក់តម្លៃ ៤ម៉ឺនរៀលក្នុងមួយគីឡូក្រាម រីឯជ្រូកកណ្តុរវិញ មានតម្លៃ ៤,៨ ម៉ឺនរៀល ក្នុងមួយគីឡូក្រាម៕ *ដោយ ម៉ែន ខែមរៈ* *ប្រភព៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ ២០២១*

## ការនាំចូលមាន់រស់នៅតែបន្ត ខណៈកម្ពុជាមានសមត្ថភាពផ្គត់ផ្គង់គ្រប់គ្រាន់



*ប្រភព ៖ ខេមបូណូមីស*

បច្ចុប្បន្ន ការនាំចូលសត្វមាន់រស់ពីខាងក្រៅ បានបង្កផលប៉ះពាល់ដល់ក្រុមអ្នកចិញ្ចឹមមាន់ក្នុងស្រុក ពិសេស ចំពោះអ្នកដែលចិញ្ចឹមមាន់សាច់។

កាលពីមុនកម្ពុជា បាននាំចូលសត្វមាន់រស់ប្រមាណ ៥ម៉ឺនក្បាលក្នុងមួយថ្ងៃ បច្ចុប្បន្ន បានកាត់បន្ថយឱ្យមានការនាំចូលសត្វមាន់រស់មកនៅត្រឹមប្រមាណ១ម៉ឺនក្បាលប៉ុណ្ណោះក្នុងមួយថ្ងៃ។

អាជ្ញាធរនៅតាមបណ្តាខេត្ត ដែលជាប់ព្រំដែនប្រទេសទាំងអស់ បានបង្កើនការរឹតត្បិត ដើម្បីបញ្ឈប់ការនាំចូលមាន់រស់ទាំងស្រុង នាពេលខាងមុខ។ សមាគមអ្នកចិញ្ចឹមសត្វកម្ពុជា ស្នើឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធ ចាត់វិធានការបន្ទាន់ ដើម្បីដោះស្រាយបញ្ហាជូនកសិករចិញ្ចឹមមាន់ក្នុងស្រុកដែលកំពុងជួបបញ្ហាទីផ្សារ ពិបាកប្រកួតប្រជែងនឹងមាន់នាំចូល។

ប្រធានសមាគមអ្នកចិញ្ចឹមសត្វកម្ពុជា បានអះអាងថា បច្ចុប្បន្នកំណើននៃការចិញ្ចឹមមាន់កាន់តែកើនឡើង ពិសេសអំឡុងវិបត្តិកូវីដ-១៩ ដែលធ្វើឱ្យក្រុមអ្នកចិញ្ចឹមមាន់ក្នុងស្រុក មានលទ្ធភាពគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុកខ្លួនឯង ដោយមិនចាំបាច់នាំចូលពីខាងក្រៅបន្ថែមនោះទេ។

សកម្មភាពនៃការនាំចូលសត្វពីប្រទេសជិតខាង បានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ក្រុមកសិករក្នុងស្រុក និងបានធ្វើឱ្យតម្លៃធ្លាក់ចុះ។ ទោះជាបែបនេះក្តី ការចិញ្ចឹមមាន់ស្រែ និងការចិញ្ចឹមមាន់សាច់ ដែលមានកិច្ចសន្យាទទួលទិញត្រឹមត្រូវពីក្រុមហ៊ុន គឺមិនសូវរងផលប៉ះពាល់ទីផ្សារនោះទេ។

លោក ឡេង ស៊ីវុទ្ធី អ្នកចិញ្ចឹមមាន់ស្រែ ខេត្តកំពង់ស្ពឺ បានអះអាងថា បច្ចុប្បន្នទីផ្សារមាន់របស់លោក មិនមានបញ្ហាអ្វីនោះទេ។ មាន់របស់លោកមានទីផ្សារស្រាប់ ទើបអាចលក់បានជាធម្មតា ដោយមាន់១គីឡូក្រាម អាចលក់បាន ១៧០០០រៀល ទៅ ១៨០០០រៀល ក្នុងមួយគីឡូក្រាម។ បច្ចុប្បន្ន មាន់បីសាសន៍ មានតម្លៃ ៧ពាន់រៀល ក្នុងមួយគីឡូក្រាម មាន់សាច់តម្លៃ ក្រោម៤ពាន់រៀល ប៉ុណ្ណោះ ក្នុងមួយគីឡូក្រាម។ បច្ចុប្បន្ន កម្ពុជាមានលទ្ធភាពផ្គត់ផ្គង់សត្វមាន់ប្រមាណ ១០ម៉ឺនក្បាល ក្នុងមួយថ្ងៃ ហើយមានតម្រូវការមាន់ប្រមាណ ១០ម៉ឺនក្បាល ក្នុងមួយថ្ងៃ ដូច្នេះ កម្ពុជាមិនចាំបាច់នាំចូលមាន់ពីក្រៅទេ នេះបើតាមការបញ្ជាក់បន្ថែមរបស់ ប្រធានសមាគមអ្នកចិញ្ចឹមសត្វកម្ពុជា៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ខេមបូឌាមីស ចេញផ្សាយថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ ២០២១*

## តារាងប្រចាំសប្តាហ៍

### តារាងទី១៖ តារាងប្រៀបធៀបតម្លៃផលិតផលនាំចេញប្រចាំខែឧសភា ឆ្នាំ២០២១

| ល.រ | ប្រភេទផលិតផល | ខែមេសា ឆ្នាំ ២០២១ | ខែឧសភា ឆ្នាំ ២០២១ | កំណើន (%) |
|---|---|---|---|---|
| | សរុបរួម | 2,008,221,567.31 | 1,062,048,024.82 | -47.11% |
| 1 | សំលៀកបំពាក់ | 349,313,803.58 | 336,921,232.72 | -3.55% |
| 2 | ស្បែកជើង | 69,622,089.72 | 75,205,173.07 | 8.02% |
| ៣ | វាយនភ័ណ្ឌ | 4,325,240.40 | 9,995,160.40 | 131.09% |
| 4 | អង្ករ | 92,619,463.17 | 26,300,253.54 | -71.60% |
| 5 | ការបូបធ្វើដំណើរ | 78,188,702.40 | 82,155,823.23 | 5.07% |
| 6 | ផលិតផលកសិកម្ម | 0.00 | 0.00 | គ្មាន |
| 7 | កង់ | 0.00 | 0.00 | គ្មាន |
| 8 | ផលិតផលផ្សេងៗ | 1,414,152,268.04 | 531,470,381.86 | -62.42% |

**បញ្ជាក់៖ ទិន្នន័យនេះមិនរាប់បញ្ចូលតំបន់សេដ្ឋកិច្ចពិសេសទេ។**

*ប្រភព៖ ក្រសួងពាណិជ្ជកម្មកម្ពុជា ចុះនាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០២១*

តារាងទី១ ខាងលើនេះបង្ហាញ ពីការប្រៀបធៀបការនាំចេញផលិតផលគ្រប់ប្រភេទក្នុងខែឧសភា ឆ្នាំ ២០២១ ដែលមានកំណើនថយ ៤៧% បើធៀបនឹងខែមេសាក្នុងឆ្នាំដូចគ្នានេះ។ ផលិតផលនាំចេញទាំងនោះ រួមមាន៖ សំលៀកបំពាក់ វាយនភ័ណ្ឌ អង្ករ ស្បែកជើង កង់ ផលិតផលកសិកម្ម កាបូបធ្វើដំណើរ និងផលិតផលផ្សេងៗ នេះបើយោងតាមព្រឹត្តិបត្រ

ពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ដែលបានចេញផ្សាយនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១។

ការនាំចេញផលិតផលនៅខែឧសភា ឆ្នាំ២០២១នេះ រួមមាន៖ អង្ករមានការធ្លាក់ចុះយ៉ាងខ្លាំងជិត ៧២% បន្ទាប់មក ផលិតផលផ្សេងៗធ្លាក់ចុះ៦២% និងសំលៀកបំពាក់ថយ ចុះបន្តិចជិត៤%។ រីឯ វាយនភ័ណ្ឌ ស្បែកជើង និងការបូបធ្វើដំណើរបានកើនឡើង ១៣១%, ៨%, ៥% រៀងគ្នា បើធៀបនឹងខែមេសាឆ្នាំដូចគ្នានេះ។ កង់ និងផលិតផលកសិកម្មពុំមានសកម្មភាពទេ៕ *ដោយ ឈេន ហាំ*

### តារាងទី២៖ តារាងប្រៀបធៀបទីផ្សារគោលដៅនាំចេញប្រចាំខែឧសភា ឆ្នាំ២០២១

| ល.រ | ទីផ្សារគោលដៅ | ខែមេសា ឆ្នាំ ២០២១ | ខែឧសភា ឆ្នាំ ២០២១ | កំណើន (%) |
|---|---|---|---|---|
| | សរុបរួម | 2,008,221,567.31 | 1,062,048,024.82 | -47.11% |
| 1 | សហរដ្ឋអាមេរិក | 226,302,906.77 | 276,268,038.72 | 22.08% |
| 2 | កាណាដា | 50,102,008.78 | 42,100,185.57 | -15.97% |
| ៣ | ជប៉ុន | 60,921,744.64 | 23,701,218.33 | -61.10% |
| 4 | សហគមអ៊ឺរ៉ុប | 88,538,003.30 | 136,434,995.41 | 54.10% |
| 5 | អាស៊ាន | 1,358,580,397.53 | 425,681,138.65 | -68.67% |
| 6 | ចិន | 107,323,175.13 | 84,735,307.17 | -21.05% |
| 7 | កូរ៉េ | 13,838,933.43 | 7,993,511.46 | -42.24% |
| 8 | ប្រទេសដទៃទៀត | 102,614,397.73 | 65,133,629.51 | -36.53% |

**បញ្ជាក់៖ ទិន្នន័យនេះមិនរាប់បញ្ចូលតំបន់សេដ្ឋកិច្ចពិសេសទេ។**

*ប្រភព៖ ក្រសួងពាណិជ្ជកម្មកម្ពុជា ចុះនាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០២១*

តារាងទី២ខាងលើនេះបង្ហាញ ពីការប្រៀបធៀបទីផ្សារគោលដៅ ឬ ប្រទេសគោលដៅ ក្នុងការនាំចេញផលិតផលគ្រប់ប្រភេទក្នុងខែឧសភា ឆ្នាំ២០២១ ដែលមានកំណើន ៤៧% បើធៀបនឹងខែមេសាក្នុងឆ្នាំដូចគ្នា។ ផលិតផលទាំងនោះរួមមាន៖ សំលៀកបំពាក់ វាយនភ័ណ្ឌ អង្ករ ស្បែកជើង កាបូបធ្វើដំណើរ និងផលិតផលផ្សេងៗ។ ផលិតផលទាំងនោះត្រូវបាននាំចេញទៅប្រទេសគោលដៅជាច្រើនដូចជា៖ សហរដ្ឋអាមេរិក កាណាដា ជប៉ុន សហគមអ៊ឺរ៉ុប អាស៊ាន ចិន កូរ៉េខាងត្បូង និងប្រទេសដទៃទៀត នេះបើយោងតាមព្រឹត្តិបត្រពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ដែលបានចេញផ្សាយនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០២១។

ទំនិញទាំងអស់ខាងលើនេះ ត្រូវបាននាំចេញទៅទីផ្សារ អាស៊ាន ជប៉ុន កូរ៉េ ប្រទេសដទៃទៀត ចិន និងកាណាដា ដោយធ្លាក់ចុះ ៦៩%, ៦១%, ៤២%, ៣៧%, ២១% ១៥ % រៀងគ្នា បើធៀបនឹងខែមេសាឆ្នាំដូចគ្នានេះ។ ចំណែក សហគមអ៊ឺរ៉ុបកើន ៥៤% និងសហរដ្ឋអាមេរិកកើន២២% បើធៀបនឹងខែមេសាក្នុងឆ្នាំដូចគ្នានេះ៕ *ដោយ ឈេន ហាំ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ពាណិជ្ជកម្មរបស់ម៉ាឡេស៊ី សម្រាប់ខែកក្កដា ឆ្នាំ ២០២១ (គិតជាពាន់លានរីងហ្គិត)

សន្ទស្សន៍តម្លៃឯកតានាំចេញ (export unit value index) របស់ប្រទេសម៉ាឡេស៊ីបានកើនឡើង ១,៣% នៅក្នុងខែកក្កដា ឆ្នាំ២០២១ ធៀបទៅនឹងខែមុន ដែលរួមចំណែកដោយកំណើន នៃសន្ទស្សន៍ឥន្ធនៈរ៉ែ (+៦,៧%) គ្រឿងម៉ាស៊ីន និងឧបករណ៍ដឹកជញ្ជូន (+១,១%) និងទំនិញឧស្សាហកម្ម (+០,៥%)។ យ៉ាងណាមិញ សន្ទស្សន៍បរិមាណនាំចេញ (export value index) បានធ្លាក់ចុះ៩% នៅក្នុងខែដដែលនេះឆ្លុះបញ្ចាំងពីការថយចុះនៃសន្ទស្សន៍គ្រឿងសម្ភារឧស្សាហកម្មផ្សេងៗ (miscellaneous manufactured articles) (-២២,៩%) ទំនិញឧស្សាហកម្ម (-១២.០%) និងគ្រឿងម៉ាស៊ីននិងឧបករណ៍ដឹកជញ្ជូន (-៧.៧%)។

បើធៀបទៅនឹងឆ្នាំមុន សន្ទស្សន៍តម្លៃឯកតានាំចេញកើនឡើង ១៤,៣% ខណៈសន្ទស្សន៍បរិមាណនាំចេញធ្លាក់ចុះ៨,២%។

សន្ទស្សន៍តម្លៃឯកតានាំចូលបានកើនឡើង ១,៣% នៅក្នុងខែកក្កដា ឆ្នាំ២០២១ ធៀបទៅនឹងខែមុន។ ការកើនឡើងនេះ ត្រូវបានជំរុញដោយកំណើនសន្ទស្សន៍ឥន្ទនៈរ៉ែ (+៨,១%) គ្រឿងម៉ាស៊ីននិងឧបករណ៍ដឹកជញ្ជូន (+0,៧%) និងទំនិញឧស្សាហកម្ម (+0,៤%)។ ផ្ទុយទៅវិញ សន្ទស្សន៍បរិមាណនាំចូលបានធ្លាក់ចុះ 0,៨% នៅក្នុងខែដូចគ្នា ធៀបទៅនឹងខែមុន ដោយសារការធ្លាក់ចុះ នៃសន្ទស្សន៍ខ្លាញ់សត្វនិងបន្លែ និងខ្លាញ់(-១៩,១%) ទំនិញឧស្សាហកម្ម (-១៣,៦%) និងសារជាតុគីមី (-9,8%)។ ជារួម បើធៀបទៅនឹងឆ្នាំមុន ទាំងតម្លៃឯកតានាំចូល និង សន្ទស្សន៍បរិមាណបានកើនឡើង ៥,៦% និង១៧,៥% រៀងៗខ្លួន៕ *ដោយ ជឹម ប៊ុនធឿន*

| | មិថុនា ឆ្នាំ២០២១ | កក្កដា ឆ្នាំ២០២១ |
|---|---|---|
| ការនាំចេញ | 105.5 | 97.3 |
| ការនាំចូល | 83.2 | 83.6 |
| តុល្យភាពពាណិជ្ជកម្ម | 22.3 | 13.7 |

*ប្រភព៖ Department of Statistics Malaysia Official Portal*

## ពាណិជ្ជកម្មថៃខែកក្កដា ឆ្នាំ២០២១ (ពាន់លានដុល្លារ)

តារាងខាងក្រោមបង្ហាញ អំពីពាណិជ្ជកម្មរបស់ប្រទេសថៃ សម្រាប់ខែកក្កដា ឆ្នាំ២០២១ ដែលការនាំចេញរបស់ថៃ បានកើនឡើងច្រើនជាងការរំពឹងទុក។

ការនាំចេញរបស់ប្រទេសថៃមានចំនួន ២២,៦៥ ពាន់លានដុល្លារ នៅក្នុងខែកក្កដា ឆ្នាំ២០២១ ពោលគឺកើនឡើង ២០,២៧% ធៀបទៅនឹងឆ្នាំមុន ដោយសារតម្រូវការពិភពលោកមានភាពប្រសើរឡើង។ តម្រូវការពីទីផ្សារសំខាន់ៗបានកើនឡើងខ្ពស់នៅក្នុងខែកក្កដា ឆ្នាំ២០២១ ដូចជា ការនាំចេញទៅសហរដ្ឋអាមេរិក កើនឡើង ២២% ពីមួយឆ្នាំទៅមួយឆ្នាំ ទៅចិនកើនឡើង ៤១% ទៅជប៉ុនកើនឡើង ២៣% និងសហភាពអឺរ៉ុបកើនឡើង ២១%។

រីឯ ការនាំចូលមានចំនួន ២២,៤៧ ពាន់លានដុល្លារ ពោលគឺកើនឡើង ៤៥,៩% នៅក្នុងខែកក្កដា ឆ្នាំ២០២១ បើធៀបទៅនឹងខែដូចគ្នាឆ្នាំ២០២០។ ជារួម ប្រទេសថៃមានអតិរេកពាណិជ្ជកម្មចំនួន ១៨៣,៤៦ លានដុល្លារ សម្រាប់ខែកក្កដា ឆ្នាំ២០២១។

គួរកត់សម្គាល់ផងដែរ នៅក្នុងរយៈពេល 0៧ខែ ពីខែមករា ដល់ ខែកក្កដា ឆ្នាំ២០២១ ការនាំចេញបានកើនឡើង ១៦,២% បើធៀបទៅនឹងរយៈពេល0៧ខែឆ្នាំមុន ខណៈការនាំចូលបានកើនឡើង ២៨,៧% ដែលនាំឱ្យប្រទេសថៃមានអតិរេកពាណិជ្ជកម្មចំនួន ២,៦ ពាន់លានដុល្លារ។៕ *ដោយ ជឹម ប៊ុនធឿន*

| | **កក្កដា ឆ្នាំ២០២១** |
|---|---|
| **ការនាំចេញ** | 22.65 |
| **ការនាំចូល** | 22.47 |
| **តុល្យភាពពាណិជ្ជកម្ម** | 0.18 |

*ប្រភព៖ bot*

## តើចរន្តទិញទំនិញតាមអនឡាញនៅអាស៊ីអាគ្នេយ៍កើនឡើងកម្រិតណាក្នុងអំឡុងពេលវិបត្តិកូវីដ-១៩?



*ប្រភព ៖ ខេមបូណូមីស*

តាមរយៈវិធានការរឹតបន្តឹងក្នុងការធ្វើដំណើរប្រចាំថ្ងៃចាប់តាំងពីមានជំងឺកូវីដ១៩មក មនុស្សជាច្រើនបាន

ផ្លាស់ប្តូរទម្លាប់ពីការទិញទំនិញផ្ទាល់ មកទិញតាមប្រព័ន្ធអនឡាញវិញម្តង។ ប្រការនេះបានធ្វើឱ្យទីផ្សារតាមប្រព័ន្ធអនឡាញមានការកើនឡើងកាន់តែច្រើន។ ប្រទេសជាច្រើនក្នុងតំបន់អាស៊ីអាគ្នេយ៍ បាននិងកំពុងពង្រីកការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈប្រព័ន្ធអនឡាញ ដែលជំរុញឱ្យមានការផ្លាស់ប្តូរបែបឌីជីថលមួយដ៏ល្អប្រសើរ។ ជាក់ស្តែងបើតាមការស្ទង់មតិពីមនុស្សជាង ១ម៉ឺន៦ពាន់នាក់ ដែលរស់នៅក្នុងប្រទេសសិង្ហបុរី ម៉ាឡេស៊ី ហ្វីលីពីន ឥណ្ឌូនេស៊ី ថៃ និងវៀតណាម ត្រូវបានរកឃើញថា ពួកគេរីករាយនឹងទទួលយកការផ្លាស់ប្តូរបែបឌីជីថលបានយ៉ាងរហ័សក្នុងអំឡុងពេលមានជំងឺរាតត្បាតកូវីដ១៩នេះ។

បើតាមការព្យាករណ៍ពីពេលនេះរហូតដល់ចុងឆ្នាំ ២០២១ គេរំពឹងថាប្រទេសនីមួយៗនៅអាស៊ីអាគ្នេយ៍នឹងមានប្រជាជនពេញវ័យពី៧០% ឬច្រើនជាងនេះ ដែលជាអ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល។ តួលេខនេះជាតួលេខមួយខ្ពស់ដោយហេតុថា វាជាតួលេខដែលកើនឡើងលឿនជាងប្រទេសធំៗជាច្រើនដូចជា ឥណ្ឌា ប្រេស៊ីល និងប្រទេសចិនផងដែរ។

នៅឆ្នាំ២០២០ ការចំណាយលើអនឡាញសម្រាប់មនុស្សម្នាក់នៅអាស៊ីអាគ្នេយ៍ មានជិត២៤០ដុល្លារក្នុងមួយឆ្នាំ ហើយត្រូវបានគេរំពឹងថា នឹងកើនដល់ជិត ៣៩០ដុល្លារ នាឆ្នាំ២០២១។ ប្រទេសដែលមានអ្នកទិញតាមអនឡាញ ច្រើនជាងគេ នៅតំបន់អាស៊ីអាគ្នេយ៍ រួមមានឥណ្ឌូនេស៊ី ហ្វីលីពីន ម៉ាឡេស៊ី សិង្ហបុរី និងវៀតណាម។ ហើយបើប្រទេសទាំងនេះ រួមបញ្ចូលគ្នាទៅគឺច្រើនជាងប្រទេសចិន។

គួរកត់សម្គាល់ដែរថា មិនត្រឹមតែការទិញទំនិញតាមអនឡាញនោះទេដែលមានការកើនឡើង សូម្បីតែការប្រើប្រាស់បណ្តាញសង្គមក៏កើនឡើងខ្ពស់ផងដែរ។ ជាក់ស្តែង បើគិតត្រឹមត្រីមាសទី២នៃឆ្នាំនេះ ប្រជាជនប្រមាណ ៣៥០លាននាក់ នៅអាស៊ីអាគ្នេយ៍ បានប្រើប្រាស់បណ្តាញសង្គមហ្វេសប៊ុកជារៀងរាល់ថ្ងៃ ដែលតួលេខនេះក៏មានការកើនឡើងខ្ពស់បំផុតបើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០២១។*

## ផលិតកម្មវៀតណាមធ្លាក់ចុះ បង្អាក់ដល់ការផ្គត់ផ្គង់ជាសកល



*ប្រភព៖ VnExpress, រូបភាព៖ Quynh Tran*

ធនាគារ HSBC បានលើកឡើងថា ការធ្លាក់ចុះនៃ ការផលិតនៅក្នុងឧស្សាហកម្មវាយនភ័ណ្ឌ និងស្បែកជើងរបស់វៀតណាម ដោយសារជំងឺកូវីដ ១៩ បានជះឥទ្ធិពលដល់សង្វាក់ផ្គត់ផ្គង់ពិភពលោក។ អ្នកប្រើប្រាស់នៅអាមេរិក និងអឺរ៉ុប នឹងទទួលរងនូវការរំខាននេះ ជាពិសេសនៅពេលរដូវបុណ្យចូលមកដល់។

យោងតាមសមាគមវាយនភ័ណ្ឌ និងកាត់ដេរវៀតណាម បានឱ្យដឹងថារោងចក្រកាត់ដេរសម្លៀកបំពាក់ជិត ៣៥%នៅក្នុងប្រទេសត្រូវបានបិទទ្វារ។

ប្រទេសវៀតណាម គឺជាប្រទេសផលិតវាយនភ័ណ្ឌ និងសំលៀកបំពាក់ ធំបំផុតទីបី របស់ពិភពលោក បន្ទាប់ពីប្រទេសចិន និងបង់ក្លាដែស។ ចំណែកទីផ្សារនៃឧស្សាហកម្មស្បែក និងស្បែកជើង គឺ ១៥% បន្ទាប់ពីកើនឡើងទ្វេដងក្នុងទសវត្សចុងក្រោយនេះ។

ការផ្គត់ផ្គង់របស់ក្រុមហ៊ុនសម្លៀកបំពាក់កីឡាអន្តរជាតិ Nike និង Adidas គឺជាឧទាហរណ៍ដ៏ចម្បងមួយ

ដែលបង្ហាញពីសារៈសំខាន់របស់វៀតណាមនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ពិភពលោក។ ក្នុងចំណោមរោងចក្រចំនួន ១១២ របស់ខ្លួនមានរោងចក្រចំនួន ៨៨ នៅប្រទេសវៀតណាម និងផលិតពាក់កណ្តាលនៃផលិតផលស្បែកជើងទាំងអស់។

រលកនៃជំងឺកូវីដ១៩ បំរ៉ែបំរួលថ្មី Delta បានវាយប្រហារប្រទេសនេះ និងបង្កឱ្យមានសំនួរអំពីលទ្ធភាពនៃសង្វាក់ផ្គត់ផ្គង់របស់វៀតណាមយ៉ាងខ្លាំង ដូច្នេះ Apple និង Google បានពន្យារពេលការផ្លាស់ប្តូរទៅប្រទេសវៀតណាម។ ធនាគារ HSBC បានបន្ថែមថាផែនការដើម្បីរស់នៅជាមួយកូវីដ-១៩ ដែលរដ្ឋាភិបាលវៀតណាម មានគោលបំណងភាគច្រើនពឹងផ្អែកលើសមត្ថភាព ដើម្បីសម្រេចបានអត្រាចាក់វ៉ាក់សាំងទូលំទូលាយ។ ទោះបីជាយ៉ាងណា វៀតណាម នៅតែដើរយឺតជាងប្រទេសដទៃទៀតក្នុងតំបន់ក្នុងការបញ្ជាទិញ និងប្រើប្រាស់វ៉ាក់សាំង។

ជាមួយគ្នានេះ វៀតណាមទទួលបាន ២១,២ ប៊ីលានដុល្លារ ពីការនាំចេញសម្លៀកបំពាក់និងវាយនភ័ណ្ឌ និង ១២,៦ ប៊ីលានដុល្លារ ពីការនាំចេញស្បែកជើង ក្នុងរយៈពេល ៨ខែដំបូងនៃឆ្នាំនេះ កើនឡើង៩,៧% និង ១៦,២%រៀងៗគ្នា នេះបើយោងតាមការិយាល័យស្ថិតិទូទៅ។ *ដោយ វិត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន VNExpress ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១*

## ម៉ាឡេស៊ីគ្រោងនឹងបង្កើនពិដានបំណុលរដ្ឋាភិបាល ដល់ ៦៥% នៃផ.ស.ស



*ប្រភព៖ CNA, រូបភាព៖ Nazry Rapaai*

គណៈរដ្ឋមន្ត្រីម៉ាឡេស៊ី បានស្នើបង្កើនបញ្ញត្តិពិដានបំណុលរបស់រដ្ឋាភិបាលដល់ ៦៥% នៃផ.ស.ស ដែលជាផ្នែកមួយនៃវិធានការដើម្បីដោះស្រាយវិបត្តិសេដ្ឋកិច្ច នៃជំងឺកូវីដ១៩ នេះជាលើកទី២ហើយ ក្នុងរយៈពេលជាច្រើនឆ្នាំ ដែលរដ្ឋាភិបាលបានព្យាយាមបង្កើនពិបានបំណុលរបស់ខ្លួន។ នៅឆ្នាំ ២០២០ ពិដាននេះត្រូវបានបង្កើនដល់ ៦០%នៃ ផ.ស.ស. ដែលជាការកើនឡើងលើកដំបូងចាប់តាំងពីខែកក្កដា ឆ្នាំ២០០៩។

គណៈរដ្ឋមន្ត្រី ក៏បានស្នើបង្កើនទំហំនៃមូលនិធិកូវីដ១៩ របស់រដ្ឋាភិបាលដល់ ១១០ ប៊ីលានរីងហ្គីត (២៦.៥៣ ប៊ីលានដុល្លារ) ពី ៦៥ ប៊ីលានរីងហ្គីត (១៥.៦៧ ប៊ីលានដុល្លារ) ខណៈដែលសំណើទាំងពីរនេះនឹងត្រូវបញ្ជូនទៅសភានៅខែតុលា ដើម្បីអនុម័ត និងមានគោលបំណងពង្រឹងប្រព័ន្ធសុខភាពសាធារណៈ កែលម្អវិធានការជំនួយសង្គម និងផ្តល់ការគាំទ្រដល់អាជីវកម្ម។ ទន្ទឹមនឹងនេះ ក្រសួងហិរញ្ញវត្ថុ ក៏បានណែនាំឱ្យធនាគារពិនិត្យមើលការទូទាត់ការប្រាក់សម្រាប់អ្នកខ្ចីដែលមានចំណូលទាប ដែលបានទទួលការពន្យារពេលប្រាក់កម្ចីរបស់ពួកគេ។

ដោយឡែកប្រទេសម៉ាឡេស៊ី បានកាត់បន្ថយទស្សនវិស័យកំណើនសេដ្ឋកិច្ចឆ្នាំ ២០២១ របស់ខ្លួនពីរដង

នៅឆ្នាំនេះ ដោយសារវិធានការបិទខ្ទប់ថ្មីបានបន្ថយការងើបឡើងវិញនៃសេដ្ឋកិច្ច ហើយឥឡូវនេះរំពឹងថាសេដ្ឋកិច្ចនឹងកើនពី ៣% ទៅ ៤% ទាបជាងពីការព្យាករពីមុនពី ៦% ទៅ ៧,៥%។ រដ្ឋាភិបាលគ្រោងនឹងរៀបចំថវិការបស់ខ្លួនសម្រាប់ឆ្នាំ ២០២២ ដោយផ្តល់អាទិភាពដល់ការស្តារឡើងវិញ និងការកែទម្រង់ក្រោយជំងឺរាតត្បាត។ *ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន channelnewsasia.com ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២១*

## ថៃ ជំរុញការនាំចេញផ្លែទុរេនកាន់តែខ្លាំង



*ដោយ ខេមបូណ្ឌមីស*

ទុរេនថៃ ត្រូវបានគេស្គាល់ជាយូរមកហើយ ដោយសារគុណភាពខ្ពស់ និងរសជាតិ ហើយបានចុះបញ្ជីម៉ាកផលិតផលសម្គាល់ភូមិសាស្ត្រ GI ដែលបន្ថែមគុណតម្លៃដល់ផ្លែទុរេនថៃ។ ប្រទេសថៃ បានបង្ហាញពីគោលបំណង ក្នុងការផ្សព្វផ្សាយអំពីផ្លែទុរេនឱ្យក្លាយជាផលិតផលពិសេស ដើម្បីជំរុញការនាំចេញ។

ផ្លែទុរេន ជាផលិតផលកសិកម្មនាំចេញកំពូលរបស់ថៃ ដោយសម្រេចបានជិត ៣ពាន់លានដុល្លារអាមេរិក ស្មើនឹង២,៥% នៃផលិតផលក្នុងស្រុកសរុបរបស់ថៃ ហើយមានអត្រាកំណើនជាមធ្យម ៤០% ក្នុងមួយឆ្នាំ។

ក្នុងរយៈពេល៩ខែដើមឆ្នាំ២០២១នេះ ប្រទេសថៃបាននាំចេញទុរេនស្រស់ប្រមាណ ១៨០០លានដុល្លារអាមេរិក កើនឡើង៤៥% ធៀបនឹងពេលដូចគ្នាកាលពីឆ្នាំមុន ហើយថៃ អាចនឹងសម្រេចការនាំចេញទុរេនស្រស់ជិត ៣០០០លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០២១នេះ កើនឡើងជាង៤០% ធៀបនឹងឆ្នាំ ២០២០៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០២១*

## សេដ្ឋកិច្ចសកល

### គណបក្សប្រជាធិបតេយ្យនៃសហរដ្ឋអាមេរិក បានស្នើដំឡើងពន្ធលើមូលធនដល់ទៅ ២៨,៨%




*ប្រភព៖ cnbc.២០២១, រូបភាព៖ Drew Angerer |Getty Images*

កាលពីថ្ងៃចន្ទ ទី១៣ ខែកញ្ញានេះ គណបក្សប្រជា-ធិបតេយ្យបានធ្វើការស្នើដំឡើងអត្រាពន្ធលើការចំណេញមូលធន និងភាគលាភដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងអត្រា ២៨,៨% ដែលជាកំណែទម្រង់ពន្ធមួយ ក្នុងចំណោមកំណែទម្រង់ពន្ធជាច្រើនដែលមានបំណងឱ្យជនជាតិអាមេរិកដែលមានទ្រព្យសម្បត្តិ ជួយផ្តល់ថវិកាដល់ផែនការថវិកាចំនួន ៣,៥ ទ្រីលានដុល្លារ។

អត្រាពន្ធដែលកំណត់ដោយ រដ្ឋបាលសហព័ន្ធ មានអត្រា ២៥% លើការចំណេញពីមូលធនរយៈពេលវែង ដែលជាការកើនឡើងពី ២០% លើអត្រាដែលមានស្រាប់ (ការចំណេញមូលធនរយៈពេលវែងត្រូវបានដាក់ទៅលើទ្រព្យសកម្មដែលត្រូវបានលក់បន្ទាប់ពីមានកម្មសិទ្ធិលើសពីមួយឆ្នាំ)។ ក្នុងនោះ មានការ

បន្ថែមលើពន្ធបន្ថែមដែលមានស្រាប់ ចំនួន៣,៨% ដែលមានស្រាប់ លើប្រាក់ចំណូលវិនិយោគសុទ្ធ ដូចនេះ ពន្ធសរុបនឹងមានចំនួន ២៨,៨%។ អត្រាថ្មីនេះនឹងអនុវត្តចំពោះភាគហ៊ុន និងការលក់ទ្រព្យសម្បត្តិផ្សេងទៀត បន្ទាប់ពីថ្ងៃទី១៣ ខែកញ្ញាឆ្នាំ២០២១ ជាកាលបរិច្ឆេទដែលសមាជិកសភាមកពីគណបក្សប្រជាធិបតេយ្យបានណែនាំអំពីផ្នែកពន្ធនៃបញ្ញត្តិរបស់ខ្លួន។

យោងតាមលេខាធិការដ្ឋានរបស់គណៈកម្មាធិការ House Ways and Means Committee aide នៅឆ្នាំ ២០២២ សហរដ្ឋអាមេរិកចាប់ផ្ដើមអនុវត្តចំពោះ អ្នកបង់ពន្ធក្នុងអត្រាខ្ពស់បំផុតរបស់រដ្ឋបាលសហព័ន្ធ ប្រសិនបើប្រាក់ចំណូលជាប់ពន្ធរបស់ពួកគេលើសពី ៤០០ ០០០ ដុល្លារ (នៅលីវ), ៤២៥ ០០០ ដុល្លារ (មេគ្រួសារ) និង ៤៥០ ០០០ ដុល្លារ (រៀបការ)។ ការកំណត់នេះគឺស្របតាមរដ្ឋបាលរបស់លោកប្រធានាធិបតីដែលសន្យាថានឹងមិនដំឡើងពន្ធសម្រាប់គ្រួសារដែលរកបាន តិចជាង ៤០ ម៉ឺនដុល្លារទេ។ ទោះយ៉ាងណាក៏ដោយ ការកំណត់អត្រានេះទាបជាងកម្រិតប្រាក់ចំណូលបច្ចុប្បន្ន ដែលត្រូវបានអនុវត្ត។ គោលនយោបាយបង្កើនមូលធននេះ ខុសគ្នាពីគោលនយោបាយ ដែលរដ្ឋបាលបានលើកឡើងកាលពីមុន ដែលបានទាមទារឱ្យមានអត្រារួមបញ្ចូលគ្នា ៤៣,៤% លើអ្នកដែលមានប្រាក់ចំណូលលើសពី ១ លានដុល្លារ។ ទន្ទឹមនឹងនេះ ក្រុមប្រជាធិបតេយ្យនៅសភាហាក់ដូចជាបានលុបចោលនូវសំណើរបស់រដ្ឋបាល លោកប្រធានាធិបតី ដែលយកពន្ធលើការចំណេញមូលធននៅពេលមរណៈភាពរបស់ម្ចាស់ទ្រព្យ។

គណបក្សប្រជាធិបតេយ្យមានគោលបំណងយ៉ាងទូលំទូលាយដើម្បីធ្វើឱ្យគោលនយោបាយពន្ធមានភាពស្មើគ្នានិងបង្កើនប្រាក់រាប់ពាន់លានដុល្លារដើម្បីពង្រីកបណ្ដាញសុវត្ថិភាពសង្គមរបស់ប្រទេស និងធ្វើការវិនិយោគ ដើម្បីទប់ស្កាត់ការប្រែប្រួលអាកាសធាតុ។ ការផ្លាស់ប្ដូរទាំងនោះត្រូវបានគេរំពឹងថានឹងចំណាយរហូតដល់ ៣,៥ ទ្រីលានដុល្លារ។ ការបង្កើនអត្រាពន្ធលើប្រាក់ចំណេញមូលធន (និងការបន្ថយកម្រិតប្រាក់ចំណូលដែលអត្រាខាងលើត្រូវបានអនុវត្ត នឹងបង្កើនប្រាក់ចំនួន ១២៣ប៊ីលានដុល្លារក្នុងរយៈពេលមួយទសវត្សរ៍ខាងមុខនេះ បើយោងតាមការប៉ាន់ប្រមាណរបស់គណៈកម្មាធិការចម្រុះពន្ធដារ។

ទោះយ៉ាងណាក៏ដោយ សំណើពន្ធរបស់ House Democrats មិនមែនជាដំណោះស្រាយចុងក្រោយនោះទេ។ ព្រឹទ្ធសភានៃគណបក្សប្រជាធិបតេយ្យអាចនឹងស្វែងរកការកែទម្រង់ផ្សេងៗ។ បន្ថែមពីលើការបង្កើនអត្រាពន្ធលើមូលធន សភានឹងបង្កើតពន្ធបន្ថែម៣% លើប្រាក់ចំណូលសរុបដែលបានកែសម្រួលរបស់បុគ្គលមានចំណូលលើសពី ៥លានដុល្លារដោយចាប់ផ្ដើមពីឆ្នាំ ២០២២ ក្នុងនោះមានការបង្កើនអត្រាពន្ធលើប្រាក់ចំណូលបន្ថែម ដល់ ៣៩,៦% ពី ៣៧% ផងដែរ។ ក្នុងចំណោមកំណែទម្រង់ផ្សេងទៀត វាក៏នឹងជួយកាត់បន្ថយការលើកលែងពន្ធលើអចលនទ្រព្យ (ដល់៥លានដុល្លារពីបច្ចុប្បន្ន ១១,៧ លានដុល្លារសម្រាប់បុគ្គល) និងផ្លាស់ប្ដូររបៀបដែលអ្នកមានប្រើគណនីចូលនិវត្តន៍បុគ្គលនិងផែនការ។ ចំណូលពន្ធនេះក៏នឹងផ្ដល់ថវិកាចំនួន ៧៨,៩ ប៊ីលានដុល្លារដល់ IRS ដើម្បីពង្រឹងការអនុវត្តពន្ធសម្រាប់អ្នកបង់ពន្ធដែលរកចំណូលបានជាង ៤០ ម៉ឺនដុល្លារក្នុងមួយឆ្នាំ៕

*ដោយ សេន ចន្នី*

*ប្រភព៖ cnbc,ចេញផ្សាយថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១*

## កំណើននៃការរីករាលដាលជំងឺកូវីដ១៩-បំប្លែងថ្មី អាចធ្វើឱ្យមូលនិធិសមធម៌នៃសហរដ្ឋអាមេរិក ប្រឈមមុខនឹងលំហូរចេញ




*ប្រភព៖ Reuters.២០២១, រូបភាព៖ Andrew Kelly*

មូលនិធិសមធម៌សហរដ្ឋអាមេរិកប្រឈមនឹងការហូរចេញ ដោយសារការព្រួយបារម្ភពីការរីករាលដាលនៃវីរុសកូរ៉ូណាប្រភេទ Delta ដែលនឹងអាចពន្យឺតកំណើនសេដ្ឋកិច្ច និងផ្តល់នូវភាពមិនច្បាស់លាស់លើពេលវេលាកំណត់ សម្រាប់ធនាគារកណ្តាលអាមេរិកក្នុងការដកគោលនយោបាយសម្របសម្រួលរបស់ខ្លួនមកវិញ។

តាមរយៈទិន្នន័យពី Lipper បានបង្ហាញថាមូលនិធិសមធម៌របស់អាមេរិកប្រឈមនឹងលំហូរចេញចំនួន ១,៨៥បីលានដុល្លារក្នុងដើមសប្តាហ៍ បើប្រៀបធៀបទៅនឹងលំហូរចូលដែលមានតម្លៃ ១១,១៨ ប៊ីលានដុល្លារកាលពីសប្តាហ៍មុន។

នៅក្នុងខែសីហា វិនិយោគិនក៏បានវាយតម្លៃទិន្នន័យដែលបង្ហាញថាសេដ្ឋកិច្ចអាមេរិកបានបង្កើតការងារតិចតួចបំផុតក្នុងរយៈពេល៧ខែដំបូង ដែលនឹងធ្វើឱ្យមានការប្រឈមនូវហានិភ័យនានា។

មូលនិធិកំណើនសមធម៌របស់អាមេរិកប្រឈមនឹងការលក់ដុលចំនួន ៤,៧២ប៊ីលានដុល្លារ ដែលជាលំហូរធំបំផុត ក្នុងរយៈពេល ៧ សប្តាហ៍ ខណៈដែលតម្លៃមូលនិធិបានហូរចេញក្នុងរយៈពេលសប្តាហ៍ជាប់គ្នាកន្លងមកនេះមានចំនួនតម្លៃ ៥៤១ លានដុល្លារ។ ក្នុងចំណោមមូលនិធិសមធម៌តាមវិស័យ គឺមូលនិធិអចលនទ្រព្យបានទាក់ទាញប្រាក់ចំនួន ២,២៩ប៊ីលានដុល្លារ ដែលជាចំនួនធំបំផុតចាប់តាំងពីពាក់កណ្តាលខែតុលាឆ្នាំ ២០១៩។

ចំណែកវិស័យហិរញ្ញវត្ថុ ឧស្សាហកម្ម និងសម្ភារៈប្រឈម នឹងលំហូរចេញចំនួន ១,០៥ប៊ីលានដុល្លារ ៨៥៧ លានដុល្លារនិង ៥១២ លានដុល្លាររៀងគ្នា។

ទន្ទឹមនឹងនេះដែរ មូលបត្របំណុលរបស់អាមេរិក បានទាក់ទាញប្រាក់ចំនួន ៥,២៩ប៊ីលានដុល្លារ ក្នុងរយៈពេល ៨សប្តាហ៍ ជាប់ៗគ្នានៃលំហូរចូល។ មូលបត្របំណុលជាប់ពន្ធរបស់អាមេរិកទទួលបាន ៤,៧៤ ប៊ីលានដុល្លារ ដែលជាការធ្លាក់ចុះ ៤០%ពីសប្តាហ៍មុន ខណៈពេលដែលមូលបត្របំណុលរដ្ឋរបស់អាមេរិកទាក់ទាញបាន ៨៣៣ លានដុល្លារដែលជាលំហូរចូលតិចបំផុតក្នុងរយៈពេលជិត ៤ ខែ។ មូលនិធិការពារអតិផរណារបស់អាមេរិកបានទាញយកប្រាក់ចំនួន ១,១ប៊ីលានដុល្លារដែលជាសប្តាហ៍ទី ៧ នៃលំហូរចូល ខណៈពេលដែលរដ្ឋាភិបាលរយៈពេលខ្លី/មធ្យម និងមូលនិធិរតនាគារទទួលបាន ១,៣ប៊ីលានដុល្លារ ដែលកើនឡើង ៥៣% កាលពីសប្តាហ៍មុន។ ទោះយ៉ាងណា មូលនិធិទីផ្សាររូបិយប័ណ្ណអាមេរិកបានប្រឈមនឹងលំហូរចេញក្នុងសប្តាហ៍ទី ២ ដែលមានតម្លៃ ៥,៦៩ប៊ីលានដុល្លារ៕ *ដោយ សេន ចន្ទី*

*ប្រភព៖ reuters,ចេញផ្សាយថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១*

## ធនាគារកណ្តាលចំនួន៤ប្រទេស នឹងសាកល្បងប្រើប្រាស់ប្រព័ន្ធទូទាត់ឌីជីថលឆ្លងព្រំដែន




*ប្រភព ៖ cambonomist*

ធនាគារកណ្តាលនៃប្រទេសអូស្ត្រាលី សិង្ហបុរី ម៉ាឡេស៊ី និងអាហ្វ្រិកខាងត្បូង នឹងសាកល្បងប្រើប្រាស់ប្រព័ន្ធទូទាត់ឌីជីថលឆ្លងព្រំដែន ដោយប្រើប្រាស់រូបិយប័ណ្ណឌីជីថលធនាគារកណ្តាលផ្សេងៗគ្នា ដើម្បីធ្វើឱ្យការចាយកាន់តែងាយស្រួល និងអាចកាត់បន្ថយចំណាយនៃប្រតិបត្តិការនានា។

រដ្ឋាភិបាល រួមទាំងធនាគារកណ្តាល កំពុងសិក្សាបន្ថែមពីការប្រើប្រាស់រូបិយប័ណ្ណឌីជីថលធនាគារកណ្តាល ដែលជាទម្រង់ឌីជីថលនៃរូបិយប័ណ្ណដែលមានស្រាប់។

ប្រទេសចិន ក៏កំពុងដំណើរការសាកល្បង រូបិយប័ណ្ណឌីជីថលធនាគារកណ្តាល ជាប្រភេទផ្តោតទៅលើការចាយរាយ ដើម្បីចម្លងសាច់ប្រាក់នៅក្នុងលំហូរសេដ្ឋកិច្ច ខណៈ បណ្តាប្រទេសដទៃទៀត កំពុងពិចារណាប្រើប្រាស់ ប្រភេទផ្តោតទៅលើការចាយដុំ ដើម្បីកែលម្អដំណើរការផ្ទៃក្នុង នៃប្រព័ន្ធហិរញ្ញវត្ថុរបស់ពួកគេ។

គម្រោងជាច្រើន គឺស្ថិតនៅក្នុងដំណាក់កាលដំបូងប៉ុណ្ណោះ និងផ្តោតទៅលើតែសេដ្ឋកិច្ចក្នុងស្រុក តែសម្រាប់ការអភិវឌ្ឍច្បាប់ និងក្របខណ្ឌពិភពលោក សម្រាប់ដំណើរការប្រើប្រាស់ រូបិយប័ណ្ណឌីជីថលធនាគារកណ្តាល នៅជុំវិញសកលលោក គឺមានបច្ចេកទេសស្មុគស្មាញណាស់។

ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (Bank of International Settlement) គឺជាអ្នកដឹកនាំគម្រោងនេះ ដែលមានបំណងអភិវឌ្ឍន៍ការទូទាត់ឆ្លងព្រំដែន ដែលប្រើប្រាស់រូបិយប័ណ្ណឌីជីថលធនាគារកណ្តាលប្រភេទផ្សេងៗគ្នា។

យ៉ាងណាក៏ដោយ គំនិតផ្តួចផ្តើមនេះ នឹងសិក្សាបន្ថែមពីបច្ចេកទេស អភិបាលកិច្ច និងការរចនាប្រតិបត្តិការ។

ធនាគារកណ្តាលនៃប្រទេសចិន ហុងកុង ថៃ និងអារ៉ាប់រួម កំពុងស្ថិតក្នុងដំណាក់កាលសិក្សា ក្នុងការប្រើប្រាស់ រូបិយប័ណ្ណឌីជីថលធនាគារកណ្តាលសម្រាប់ការទូទាត់ឆ្លងព្រំដែន។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖cambonomistចេញផ្សាយថ្ងៃទី០៦ខែកញ្ញាឆ្នាំ២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី២០ ខែកញ្ញា ឆ្នាំ២០២១

- ឱនភាពពាណិជ្ជកម្មរបស់អេស្ប៉ាញ ខែមិថុនាឆ្នាំ ២០២១
- កំណើនបំណុលរដ្ឋាភិបាលទួរគី ក្នុងខែកក្កដា ឆ្នាំ ២០២១

ថ្ងៃអង្គារ ទី២១ ខែកញ្ញា ឆ្នាំ២០២១

- តម្លៃផ្ទះថ្មីនៅកាណាដា បានកើនឡើង ០,៤% បើប្រៀបធៀបទៅនឹងខែមុននៅក្នុងខែកក្កដាឆ្នាំ ២០២១
- កំណើនលិខិតអនុញ្ញាតសាងសង់នៅសហរដ្ឋអាមេរិក ២,៣% នៅក្នុងខែកក្កដាឆ្នាំ ២០២១

ថ្ងៃពុធ ទី២២ ខែកញ្ញា ឆ្នាំ២០២១

- កំណើន ផលិតផលក្នុងស្រុកសរុបរបស់អាហ្សង់ទីន ២,៦% ក្នុងរយៈពេលបីខែគិតត្រឹមខែមីនាឆ្នាំ ២០២១
- អត្រាអតិផរណាប្រចាំឆ្នាំនៅអាហ្វ្រិកខាងត្បូងបានធ្លាក់ចុះក្នុងរយៈពេលពីរខែជាប់គ្នាមកនៅត្រឹម ៤,៦% ក្នុងខែកក្កដាឆ្នាំ ២០២១

ថ្ងៃព្រហស្បតិ៍ ទី២៣ ខែកញ្ញា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់អាហ្សង់ទីន បានកើនឡើងដល់ ១,៥៣៧ លានដុល្លារនៅខែកក្កដាឆ្នាំ ២០២១
- កំណើន ផលិតផលក្នុងស្រុកសរុបរបស់អេស្ប៉ាញបាន ១៩,៨% នៅត្រីមាសទី ២ នៃឆ្នាំ ២០២១

ថ្ងៃសុក្រ ទី២៤ ខែកញ្ញា ឆ្នាំ២០២១

- ការធ្លាក់ចុះ អត្រានីកម្មភាព នៅក្នុងប្រទេសអាហ្សង់ទីន
- ឱនភាពថវិការបស់រដ្ឋាភិបាលកាណាដាបានរួមតូច នៅខែមិថុនាឆ្នាំ ២០២១៕